# គំរូនៃ សាលាទាំងមូល សហគមន៍ទាំងមូល ក្មេងទាំងមូល

គំរូនៃ សាលាទាំងមូល សហគមន៍ទាំងមូល ក្មេងទាំងមូល (WSCC) គឺជា ការពង្រីក និង ធ្វើបច្ចុប្បន្នភាព នៃវិធីសាស្ត្ររៀបចំសម្រាប់សុខភាពនៅតាមសាលា (CSH) ។ WSCC រួមបញ្ចូលផ្នែកនៃ CSH និង គោលការណ៍នៃវិធីសាស្ត្រសម្រាប់ក្មេងទាំងមូលរបស់ ASCD* គឺដើម្បីពង្រឹងវិធីសាស្ត្រ បញ្ចូលគ្នា និង សហការគ្នា រវាង ការសិក្សា និង សុខភាព។

គំរូ WSCC យកចិត្តទុកដាក់ទៅលើក្មេង សង្កត់ធ្ងន់លើវិធីសាស្ត្រទូទាំងសាលា និង ទទួលស្គាល់ ការសិក្សា សុខភាព និង សាលារៀនដែលជាផ្នែកមួយនៃការឆ្លុះបញ្ចាំងពីសហគមន៍នៅតាមតំបន់។

## WSCC៖ គំរូ

សាលា មណ្ឌលសុខភាព ឪពុកម្តាយ និង សហគមន៍ មានគោលដៅរួមគ្នាមួយ គឺដើម្បីគាំទ្រដល់ សុខភាព និង សមិទ្ធផលនៃការសិក្សា របស់យុវវ័យ។ ការស្រាវជ្រាវបានបង្ហាញថា សុខភាពរបស់សិស្សទាក់ទងទៅនឹងសមិទ្ធិផលនៃការសិក្សារបស់ពួកគេ។ តាមរយៈនៃការសហការគ្នា វិស័យផ្សេងៗអាចធានាថា យុវវ័យគ្រប់រូប នៅគ្រប់សាលា នៅគ្រប់សហគមន៍ ទាំងអស់មាន សុខភាពល្អ សុវត្ថិភាព សកម្ម គាំទ្រ និង ខំប្រឹងប្រែង។

គំរូ WSCC បានបំពេញនូវគោលបំណងសំខាន់ៗមួយចំនួន៖

- រួមបញ្ចូលគ្នានូវ គំរូ «ក្មេងទាំងមូល» ពី ASCD ជាមួយវិធីសាស្ត្រ CSH ដែលត្រូវបានមនុស្សជាច្រើនប្រើនៅក្នុងជំនាញផ្នែក យុវវ័យ និង សុខភាពនៅតាមសាលា។
- សង្កត់ធ្ងន់ទៅលើទំនាក់ទំនងរវាងការអប់រំនិងសុខភាព ដោយដាក់ក្មេងនៅកណ្តាលនៃប្រព័ន្ធមួយដែលគេបានបង្កើតឡើងដើម្បីទ្រទ្រង់ផ្នែកទាំងពីរ។
- ផ្តល់នូវវិធីសាស្ត្រទាន់សម័យរបស់ CSH ដើម្បីធ្វើឲ្យកាន់តែស្របទៅតាមដំណើរការរបស់សាលា។

### គំរូនៃ សាលាទាំងមូល សហគមន៍ទាំងមូល ក្មេងទាំងមូល




- ក្មេងនៅកណ្តាល ស្ថិតនៅចំណុចបង្គោលនៃគំរូ ក្មេងត្រូវបានរុំព័ទ្ធដោយគោលការណ៍ពណ៌បៃតងនៃ «ក្មេងទាំងមូល» ៖ «សុខភាពល្អ សុវត្ថិភាព សកម្ម គាំទ្រ និង ខំប្រឹងប្រែង។»
- ខ្សែពណ៌សបាន បញ្ជាក់ពីលក្ខណៈ ស្របតាម សមាហរណកម្ម និង កិច្ចសហការ ដែលត្រូវការក្នុងវិស័យ សាលា សុខាភិបាល និង សហគមន៍ ដើម្បីកែលម្អ ការសិក្សា និង សុខភាព របស់ក្មេង។
- នៅក្នុងពណ៌ខៀវតំណាង ផ្នែកជាច្រើននៅតាមសាលាដែលព័ទ្ធជុំវិញក្មេង ដែលជាចំណុចសំខាន់ៗ ផ្តល់នូវប្រព័ន្ធគាំទ្រយ៉ាងពេញលេញដល់ ការសិក្សា និង សុខភាព របស់ ក្មេងម្នាក់ៗ នៅតាមសាលារៀននីមួយៗ នៅក្នុងសហគមន៍នីមួយៗ។
- ហគមន៍ តំណាងដោយពណ៌លឿង បង្ហាញថា ក្នុងខណៈពេលដែលសាលាគឺជាចំណុចដ៏សំខាន់មួយ វានៅតែជាការឆ្លុះបញ្ចាំងពីសហគមន៍របស់ខ្លួន ហើយទាមទារ មតិយោបល់ ប្រភពជំនួយ និងការសហការ ពីសហគមន៍ដើម្បីគាំទ្រដល់សិស្សរបស់ខ្លួន។

*គេធ្លាប់ស្គាល់ជា សមាគម គ្រប់គ្រង និង រៀបចំ កម្មវិធីសិក្សា


មជ្ឈមណ្ឌលសម្រាប់ទប់ស្កាត់ HIV/AIDS, Viral Hepatitis, STD, និង TB
ផ្នែក យុវវ័យ និង សុខភាពនៅសាលារៀន